# ចូរមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង

អែលឌើរ ដេវីឌ អេ បែដណា
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*យើងអាចកាន់តែមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង នៅពេលយើងមានសេចក្តីស្មោះនៅក្នុងការរៀនសូត្រ ការរស់នៅ និងការស្រឡាញ់ចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទកាន់តែច្រើនឡើង ។*

នៅក្នុងឆ្នាំ 1833 ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមាននូវការស្តីបន្ទោសយ៉ាងខ្លាំងចំពោះបងប្អូនប្រុស ដែលដឹកនាំសាសនាចក្រមួយចំនួន ឱ្យរៀបចំគ្រួសាររបស់ខ្លួនឱ្យមានរបៀបរៀបរយ (សូមមើល គ. និង ស. 93:40--50) ។ ឃ្លាជាក់លាក់មួយចេញមកពីវិវរណៈនេះ ផ្តល់ជាបាវចនាសំរាប់សារលិខិតរបស់ខ្ញុំ---"ចូរមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង"(ខ 50) ។ ខ្ញុំចង់ផ្តល់យោបល់បីចំណុច ដើម្បីឱ្យយើងម្នាក់ៗ អាចកាន់តែមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានរបស់យើងខ្លាំងឡើង ។ ខ្ញុំសូមអញ្ជើញឱ្យអ្នកស្តាប់ទាំងដោយត្រចៀក និងដួងចិត្ត ដើម្បីទទួលអារម្មណ៍ ហើយខ្ញុំអធិស្ឋានសុំឱ្យព្រះវិញ្ញាណរបស់ព្រះអម្ចាស់គង់នៅជាមួយយើងទាំងអស់គ្នា ។

**យោបល់ទីមួយៈ ការសម្តែងចេញនូវសេចក្តីស្រឡាញ់--- ហើយបង្ហាញវា ។**

យើងអាចចាប់ផ្តើមកាន់តែមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើងតាមរយៈការប្រាប់ដល់មនុស្សដែលយើងស្រឡាញ់ថា យើងស្រឡាញ់ពួកគេ ។ ការសម្តែងចេញដូច្នេះ មិនត្រូវការនូវពាក្យក្បូរក្បាច់ ឬវែងអន្លាយនោះទេ ។ យើងគួរតែសម្តែងចេញនូវសេចក្តីស្រឡាញ់ដោយស្មោះស្ម័គ្រ និងជាញឹកញាប់ដោយសាមញ្ញ ។

បងប្អូនប្រុសស្រី តើពេលណាគឺជាពេលចុងក្រោយដែលអ្នកចាប់ដៃរបស់ដៃគូដ៏អស់កល្បជានិច្ចរបស់អ្នក ហើយនិយាយថា "អូនស្រឡាញ់បង ឬបងស្រឡាញ់អូន? ឪពុកម្តាយ តើនៅពេលណាគឺជាពេលចុងក្រោយ ដែលអ្នកសម្តែងចេញនូវសេចក្តីស្រឡាញ់ដោយស្មោះស្ម័គ្រចំពោះកូនៗរបស់អ្នក? កូនៗ តើពេលណាគឺជាពេលចុងក្រោយដែលអ្នកប្រាប់ដល់ឪពុកម្តាយរបស់អ្នកថា អ្នកស្រឡាញ់ពួកគាត់?

យើងម្នាក់ៗបានដឹងរួចទៅហើយថា យើងគួរតែប្រាប់ដល់មនុស្សដែលយើងស្រឡាញ់ថា យើងស្រឡាញ់ពួកគេ ។ ប៉ុន្តែអ្វីដែលយើងដឹង គឺវាមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអ្វីដែលយើងធ្វើជានិច្ចកាលនោះទេ ។ យើងអាចមានអារម្មណ៍ មិនប្រាកដ ឆ្គង ឬប្រហែលជាខ្មាស់អៀនបន្តិចបន្តួច ។

ក្នុងនាមជាពួកសិស្សរបស់ព្រះអង្គសង្គ្រោះ យើងមិនគ្រាន់តែព្យាយាមឱ្យចេះកាន់តែច្រើនប៉ុណ្ណោះទេ ប៉ុន្តែយើងចាំបាច់ត្រូវធ្វើឱ្យកាន់តែច្រើននូវអ្វីដែលយើងដឹងថាជាការត្រឹមត្រូវ និងប្រែក្លាយជាមនុស្សកាន់តែល្អប្រសើរជានិច្ចផងដែរ ។

យើងគួរតែចងចាំថា ការនិយាយថា "ខ្ញុំស្រឡាញ់អ្នក" គឺគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ។ យើងចាំបាច់ត្រូវនិយាយថា យើងចាំបាច់ត្រូវតែធ្វើតាម ហើយសំខាន់បំផុត យើងចាំបាច់ត្រូវបង្ហាញវាជាប់ជានិច្ច។ យើងត្រូវការទាំងការសម្តែងចេញ និងការបង្ហាញនូវសេចក្តីស្រឡាញ់។

ពេលថ្មីៗនេះ ប្រធានថូម៉ាស អេស ម៉នសុន បានឱ្យដំបូន្មានថា: "ជាញឹកញាប់ យើងស្មានថា [មនុស្សនៅជុំវិញយើង] *ត្រូវតែ* ដឹងថាតើយើងស្រឡាញ់ពួកគេខ្លាំងប៉ុណ្ណា។ ប៉ុន្តែយើងគួរតែកុំស្មាន យើងគួរតែប្រាប់ឱ្យពួកគេដឹង...។ យើងនឹងមិនសោកស្តាយចំពោះពាក្យសំដីល្អ ឬការបង្ហាញពីសេចក្តីស្រឡាញ់នោះទេ។ ប៉ុន្តែការសោកស្តាយរបស់យើងនឹងកើតមាន បើសិនជារឿងទាំងនេះត្រូវបានលុបចេញពីទំនាក់ទំនងរបស់យើង ជាមួយនឹងអ្នកទាំងឡាយដែលមានន័យបំផុតចំពោះយើង" ("Finding Joy in the Journey" *Liahona* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 86)។

ពេលខ្លះនៅក្នុងការឡើងនិយាយ ឬការថ្លែងទីបន្ទាល់ក្នុងការប្រជុំសាក្រាម៉ង់ យើងស្តាប់ឮសេចក្តីថ្លែងដូចនេះថា: "ខ្ញុំដឹងថា ខ្ញុំមិនបានប្រាប់ដល់ប្រពន្ធរបស់ខ្ញុំជាញឹកញាប់ថាខ្ញុំស្រឡាញ់នាងប៉ុណ្ណានោះទេ។ នៅថ្ងៃនេះ ខ្ញុំចង់ឱ្យនាង កូនៗ និងអ្នកទាំងអស់គ្នាដឹងថា ខ្ញុំស្រឡាញ់នាង"។

ការសម្តែងចេញនូវសេចក្តីស្រឡាញ់ដូច្នេះអាចនឹងសមរម្យ។ ប៉ុន្តែនៅពេលខ្ញុំស្តាប់ឮការថ្លែងដូច្នេះ ខ្ញុំមានអារម្មណ៍ខ្មាស់អៀន ហើយនិយាយដោយស្ងាត់ៗថា ប្រពន្ធ និងកូនៗមិនគួរស្តាប់ឮទំនាក់ទំនងផ្ទាល់ខ្លួន និងកម្របង្ហាញនេះជាសាធារណៈនៅឯព្រះវិហារនោះទេ! សង្ឃឹមថា កូនៗស្តាប់ឮការសម្តែងចេញនូវសេចក្តីស្រឡាញ់នេះ ហើយមើល ឃើញការបង្ហាញសេចក្តីស្រឡាញ់រវាងឪពុកនិងម្តាយរបស់ពួកគេនេះ ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេទៀងទាត់ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បើការថ្លែងជាសាធារណៈអំពីសេចក្តីស្រឡាញ់នៅសាសនាចក្រ មានការភ្ញាក់ផ្អើល ចំពោះប្រពន្ធ និងកូនបន្តិចក៏ដោយ តែជាក់ស្តែងវាមាននូវតំរូវការមួយដើម្បីកាន់តែមានចិត្តព្យាយាម ហើយគិតគូរ ពីគេហដ្ឋានខ្លាំងឡើង។

ទំនាក់ទំនងរវាងសេចក្តីស្រឡាញ់ និងសកម្មភាពសមរម្យ ត្រូវបានបង្ហាញម្តងហើយម្តងទៀតនៅក្នុងព្រះគម្ពីរ ហើយត្រូវបានគូសចំណាំដោយការបង្រៀនរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកសាវករបស់ទ្រង់ "បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ" (យ៉ូហាន 14:15)។ ក៏ដូចជាសេចក្តីស្រឡាញ់របស់យើង និងចំពោះព្រះអម្ចាស់ គឺត្រូវបានក្លាយជាភស្តុតាង តាមរយៈការដើរជានិច្ចតាមផ្លូវរបស់ទ្រង់ (សូមមើល ចោទិយកថា 19:9) ដូច្នេះសេចក្តីស្រឡាញ់របស់យើង ចំពោះប្តី ឬប្រពន្ធ ឪពុកម្តាយ និងកូនៗត្រូវបានឆ្លុះបញ្ចាំងប្រកបដោយអំណាចបំផុត នៅក្នុងគំនិត ពាក្យសំដី និងទង្វើររបស់យើង (សូមមើល ម៉ូសាយ 4:30)។

ការមានអារម្មណ៍សេចក្តីស្រឡាញ់ដោយសុវត្ថិភាព និងខ្ជាប់ខ្ជួនមកពីប្តី ឬប្រពន្ធ ឪពុកម្តាយ ឬកូន គឺជាពរជ័យ ដ៏បរិបូរណ៍មួយ។ សេចក្តីស្រឡាញ់ដូច្នេះចិញ្ចឹម និងគាំទ្រដល់សេចក្តីជំនឿទៅលើព្រះ។ សេចក្តីស្រឡាញ់ដូច្នេះ គឺជាប្រភពនៃកម្លាំង ហើយបណ្តេញចេញនូវភាពភ័យខ្លាច (សូមមើល យ៉ូហានទី 1 4:18)។ សេចក្តីស្រឡាញ់ដូច្នេះ គឺជាបំណងប្រាថ្នានៃព្រលឹងវិញ្ញាណរបស់មនុស្សគ្រប់រូប។

យើងអាចកាន់តែមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង នៅពេលយើងសម្ដែងសេចក្ដីស្រឡាញ់---ហើយបង្ហាញសេចក្ដីស្រឡាញ់ឱ្យខ្ជាប់ខ្ជួន។

**យោបល់ទីពីរៈ ថ្លែងទីបន្ទាល់--- ហើយរស់នៅតាមទីបន្ទាល់។**

យើងក៏អាចកាន់តែមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង តាមរយៈការធ្វើទីបន្ទាល់ទៅកាន់អ្នកទាំងឡាយ ដែលយើងស្រឡាញ់អំពីរឿងទាំងឡាយដែលយើងដឹងថាជាការពិតតាមរយៈ សាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ។ ការថ្លែងទីបន្ទាល់មិនចាំបាច់ឱ្យវែងអន្លាយ ឬប្រកបដោយវោហារនោះទេ។ ហើយយើងមិនចាំបាច់រង់ចាំរហូតដល់ថ្ងៃអាទិត្យទីមួយក្នុងខែ ដើម្បីយើង ប្រកាសជាសាក្សីចំពោះរឿងទាំងឡាយថាជាការពិតនោះដែរ។ នៅក្នុងជញ្ជាំង គេហដ្ឋានរបស់យើងផ្ទាល់ យើងអាច ហើយគួរតែថ្លែងទីបន្ទាល់បរិសុទ្ធអំពីទេវភាព និងភាពពិតរបស់ព្រះវរបិតា និងព្រះរាជបុត្រា អំពីផែនការនៃសុភមង្គលដ៏មហិមា និងអំពីការស្ដារឡើងវិញ។

បងប្អូនប្រុសស្រី តើពេលណាគឺជាពេលចុងក្រោយ ដែលអ្នកថ្លែងទីបន្ទាល់ទៅកាន់ដៃគូដ៏អស់កល្បជានិច្ចរបស់អ្នក? ឪពុកម្ដាយ តើពេលណាគឺជាពេលចុងក្រោយ ដែលអ្នកបានប្រកាសធ្វើជាសាក្សីចំពោះកូនៗរបស់អ្នក អំពីរឿងដែល អ្នកបានដឹងថាជាការពិត? ហើយកូនៗ តើពេលណាគឺជាពេលចុងក្រោយ ដែលអ្នកបានចែកចាយទីបន្ទាល់របស់អ្នក ជាមួយនឹងឪពុកម្ដាយ និងគ្រួសាររបស់អ្នក?

យើងម្នាក់ៗបានដឹងរួចស្រេចហើយថា យើងគួរតែថ្លែងទីបន្ទាល់ទៅកាន់មនុស្សដែលយើងស្រឡាញ់បំផុត។ ប៉ុន្តែអ្វីដែល យើងដឹង គឺវាមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអ្វីដែលយើងធ្វើជានិច្ចកាលនោះទេ។ យើងអាចមានអារម្មណ៍មិនប្រាកដ ឆ្គង ឬប្រហែលជាខ្មាស់អៀនបន្តិចបន្តួច។

ក្នុងនាមជាពួកសិស្សរបស់ព្រះអង្គសង្គ្រោះ យើងមិនគ្រាន់តែព្យាយាមឱ្យចេះកាន់តែច្រើនប៉ុណ្ណោះទេ តែយើងចាំបាច់ត្រូវធ្វើឱ្យកាន់តែច្រើននូវអ្វីដែលយើងដឹងថាជាការត្រឹមត្រូវ និងប្រែក្លាយជាមនុស្សកាន់តែល្អប្រសើរជានិច្ចផងដែរ។

យើងគួរតែចងចាំថា ការថ្លែងទីបន្ទាល់ចេញពីដួងចិត្ត គឺគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ។ យើងចាំបាច់ត្រូវថ្លែងទីបន្ទាល់ ត្រូវតែមានបំណងពិត ហើយសំខាន់បំផុត យើងចាំបាច់ត្រូវរស់នៅតាមជាប់ជានិច្ច។ យើងត្រូវការទាំងការប្រកាស និងការរស់នៅតាមទីបន្ទាល់របស់យើង។

ទំនាក់ទំនងរវាងទីបន្ទាល់ និងសកម្មភាពសមរម្យ គឺត្រូវបានបញ្ជាក់នៅក្នុងការបង្រៀនរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកបរិសុទ្ធនៅក្រុងខឺតឡង់ៈ "ហើយអ្វីដែលព្រះវិញ្ញាណធ្វើបន្ទាល់ដល់អ្នករាល់គ្នា នោះយើងចង់ឱ្យអ្នករាល់គ្នាធ្វើដូច្នោះ" (គ. និង ស. 46:7)។ ទីបន្ទាល់របស់យើងអំពីសេចក្ដីពិតនៃដំណឹងល្អ គួរតែឆ្លុះបញ្ចាំងទាំងតាមពាក្យសំដីរបស់យើង និងទង្វើរបស់យើង។ ហើយទីបន្ទាល់របស់យើងត្រូវបានប្រកាស ហើយរស់នៅតាមប្រកបដោយអានុភាពបំផុតនៅក្នុង គេហដ្ឋានផ្ទាល់ខ្លួនរបស់យើង។

ប្តីឬប្រពន្ធ ឪពុកម្តាយ និងកូនៗ គួរតែព្យាយាមដើម្បីយកឈ្នះលើភាពស្ទាក់ស្ទើរ ភាពទើសទាល់ ឬភាពខ្មាស់អៀនអំពីការថ្លែងទីបន្ទាល់ ។ យើងគួរតែបង្កើត ហើយស្វែងរកឱកាសដើម្បីថ្លែងទីបន្ទាល់ សេចក្តីពិតនៃដំណឹងល្អ--- ហើយរស់នៅតាម ។

ទីបន្ទាល់គឺជាអ្វីដែលយើងដឹងថាជាការពិតនៅក្នុងគំនិត និងដួងចិត្តរបស់យើង តាមរយៈសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ (សូមមើល គ. និង ស. 8:2) ។ នៅពេលយើងអះអាងអំពីសេចក្តីពិត ជាជាងការដាស់តឿន ការព្រមាន ឬការចែកចាយបទពិសោធន៍គួរឱ្យចាប់អារម្មណ៍សាមញ្ញៗ នោះយើងទទួលបានព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបញ្ជាក់សេចក្តីពិតនៃពាក្យសំដីរបស់យើង ។ អំណាចនៃទីបន្ទាល់ដ៏បរិសុទ្ធ (សូមមើល អាលម៉ា 4:19) មិនមែនចេញមកពីភាសាស្មុគស្មាញ ឬជាការបង្ហាញដោយមានប្រសិទ្ធភាពនោះទេ ប៉ុន្តែវាគឺជាលទ្ធផលនៃវិវរណៈដែលបាននាំមក ដោយសមាជិកទីបីនៃក្រុមព្រះ ដែលជាព្រះវិញ្ញាណបរិសុទ្ធ ។

ការទទួលអារម្មណ៍នៃអំណាច ការស្មោះត្រង់ និងភាពខ្ជាប់ខ្ជួននៃទីបន្ទាល់មកពីប្តី ឬប្រពន្ធ ឪពុកម្តាយ ឬកូន គឺជាពរជ័យដ៏បរិបូរណ៍ ។ ទីបន្ទាល់ដូច្នេះ ការពារដល់សេចក្តីជំនឿ និងផ្តល់ជាការដឹកនាំ ។ ទីបន្ទាល់ដូច្នេះបង្កើតពន្លឺ នៅក្នុងពិភពលោកដែលសេចក្តីងងឹតកាន់តែមានខ្លាំងឡើង ។ ទីបន្ទាល់ដូច្នេះគឺជាប្រភពនៃការរំពឹងទុក ដ៏អស់កល្បជានិច្ចមួយ និងនៃសេចក្តីសុខសាន្តដ៏យូរអង្វែង ។

យើងអាចមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង នៅពេលយើងថ្លែងទីបន្ទាល់---ហើយរស់នៅតាមដោយខ្ជាប់ខ្ជួន ។

**យោបល់ទីបី: ត្រូវនៅខ្ជាប់ខ្ជួន ។**

នៅពេលកូនប្រុសរបស់យើងធំឡើង គ្រួសាររបស់យើងបានធ្វើនូវអ្វីដែលអ្នកបានធ្វើ ហើយនឹងអ្វីដែលអ្នកធ្វើនៅពេលឥឡូវនេះ ។ យើងមានការអធិស្ឋានជាគ្រួសារ ការសិក្សាព្រះគម្ពីរ និងរាត្រីជួបជុំក្រុមគ្រួសារជាទៀងទាត់ ។ ឥឡូវខ្ញុំដឹងយ៉ាងប្រាកដថាអ្វីដែលខ្ញុំនឹងនិយាយនេះ មិនធ្លាប់មាននៅក្នុងផ្ទះរបស់អ្នកទេមើលទៅ ប៉ុន្តែវាមាននៅក្នុងផ្ទះរបស់យើង ។

ពេលខ្លះស៊ិសស្ទើរ ប៊ែដណា និងខ្ញុំងឿងឆ្ងល់ថាកិច្ចខិតខំរបស់យើង ដែលធ្វើនូវរឿងសំខាន់ៗខាងវិញ្ញាណមានប្រយោជន៍ដែរឬទេ ។ ពេលអានខគម្ពីរ ស្រាប់តែមានឮសំរែកក្នុងចំណោមពួកយើងថា: "គាត់ប៉ះខ្ញុំ ហ្ន៎!" "ធ្វើឱ្យគាត់ឈប់សម្លឹងមើលខ្ញុំ!" "ម៉ាក់គាត់អុកឡុកខ្ញុំ" ជាដើម ។ ការអធិស្ឋានដោយស្មោះស្ម័គ្រ ជួនកាលត្រូវបានរំខាន ដោយការសើចកក្អឹក និងការចាក់ចង្កេះគ្នាទៅវិញ ។ ហើយដោយសារមានកូនប្រុសពីស ច្រងេងច្រងាង នោះមេរៀនរាត្រីជួបជុំក្រុមគ្រួសារមិនបានចេញលទ្ធផលនៃការស្មោះល្អជានិច្ចនោះទេ ។ ជាច្រើនដង ស៊ិសស្ទើ ប៊ែដណា និងខ្ញុំ ក្តៅក្រហាយ ដោយសារតែទម្លាប់សុចរិត ដែលយើងខិតខំបណ្តុះឱ្យមាននៅក្នុងការចិញ្ចឹមកូនយ៉ាងខ្លាំងនោះ ហាក់ដូចជាមិនចេញលទ្ធផលខាងវិញ្ញាណភ្លាមៗ ដូចដែលយើងចង់បាន និងរំពឹងទុកនោះទេ ។

នៅថ្ងៃនេះ បើសិនជាអ្នកអាចសួរដល់កូនប្រុសពេញវ័យរបស់យើងនូវអ្វីដែលពួកគេចងចាំ អំពីការអធិស្ឋានជាគ្រួសារ ការសិក្សាព្រះគម្ពីរ និងរាត្រីជួបជុំក្រុមគ្រួសារ ខ្ញុំជឿថា ខ្ញុំដឹងថាពួកគេនឹងឆ្លើយយ៉ាងណាហើយ ។ ពួកគេនឹងមិនចង់ប្រាប់អំពីការអធិស្ឋានជាក់លាក់ ឬឧទាហរណ៍អំពីការសិក្សាព្រះគម្ពីរជាក់លាក់ ឬមេរៀនរាត្រីក្រុមគ្រួសារប្រកបដោយ អត្ថន័យពិសេសមួយ នៅខណៈ

ពេលដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍ខាងវិញ្ញាណរបស់ពួកគេនោះទេ។ អ្វីដែលពួកគេនឹងនិយាយគឺពួកគេចងចាំថា ក្នុងនាមជាគ្រួសារមួយ យើងបានមានភាពខ្ជាប់ខ្ជួន។

ស៊ិស្ទើរ ប៉ែដណា និងខ្ញុំបានគិតថាការជួយដល់កូនប្រុសរបស់យើងឱ្យយល់អំពីមាតិកានៃមេរៀន ឬខគម្ពីរជាក់លាក់មួយ គឺជាលទ្ធផលចុងបញ្ចប់។ ប៉ុន្តែលទ្ធផលដូច្នោះ មិនកើតឡើងរាល់ពេល ដែលយើងសិក្សា ឬអធិស្ឋាន ឬរៀនជាមួយ គ្នានោះទេ។ ភាពខ្ជាប់ខ្ជួននៃបំណងប្រាថ្នា និងកិច្ចការរបស់យើង គឺប្រហែលជាមេរៀនដ៏មហិមាបំផុត--- ជាមេរៀនមួយដែលជួនកាលយើងមិនមានអំណរគុណពេញលេញទេ។

នៅក្នុងការិយាល័យរបស់ខ្ញុំ មានគំនូរដ៏ស្រស់ស្អាតមួយ អំពីវាលស្រែស្រូវសាលី។ គំនូរនេះគឺជាការប្រមូលផ្តុំកណ្តាប់ស្រូវដ៏ធំមួយ--- ដែលបើមើលពីចម្ងាយ វាគ្មានអ្វីដែលគួរឱ្យចាប់អារម្មណ៍ឬគួរឱ្យស្ញើចសោះ។ តាមពិតទៅ បើអ្នកទៅឈរជិតនឹងផ្ទាំងគំនូរនោះ អ្វីដែលអ្នកមើលឃើញ គឺគ្រាន់តែជាគំនូសឆ្នូត១ពណ៌មាស ពណ៌លឿង និងពណ៌ត្នោតយ៉ាងច្រើនមួយដែលហាក់ដូចជាមិនគូជាប់គ្នា ឬគួរឱ្យចាប់អារម្មណ៍ទេ។ ទោះជាយ៉ាងណា នៅពេលអ្នកដើរចេញពីផ្ទាំងគំនូរបន្តិចម្តង១ គំនូរគួរស្រូវនីមួយ១ទាំងនោះប្រមូលផ្តុំគ្នា ហើយ បង្កើតបានជាទេសភាពវាលស្រូវដ៏ស្រស់ស្អាតមួយ។ គំនូសឆ្នូតសាមញ្ញនៃគួរស្រូវនីមួយ១ជាច្រើននេះ ប្រមូលផ្តុំគ្នាបង្កើតបានជារូបភាពជាប់ចិត្ត និងស្រស់ស្អាត។

ការអធិស្ឋានជាគ្រួសារ កិច្ចការនៃការសិក្សាព្រះគម្ពីរ និងរាត្រីជួបជុំក្រុមគ្រួសារនីមួយ១ គឺជាគំនូសឆ្នូត១ នៅលើផ្ទាំងគំនូរនៃព្រលឹងរបស់យើង។ ព្រឹត្តការណ៍មួយអាចនឹងមិនបង្ហាញថា វាគួរឱ្យចាប់អារម្មណ៍ និងគួរឱ្យចងចាំនោះទេ។ ប៉ុន្តែដូច ជាគំនូសឆ្នូត១ពណ៌លឿង ពណ៌មាស និងពណ៌ត្នោតនៅក្នុងគំនូរ បំពេញឱ្យគ្នាទៅវិញទៅមក ហើយបង្កើតបាន ជាស្នាដៃឯក គួរឱ្យចាប់អារម្មណ៍ដូច្នេះការខ្ជាប់ខ្ជួនរបស់យើងនៅក្នុងការធ្វើរឿងដែលមើលទៅហាក់ដូចជាតូច១ អាចដឹកនាំទៅរកលទ្ធផលខាងវិញ្ញាណដ៏សំខាន់។ "ហេតុដូច្នោះហើយ ចូរកុំណាយចិត្តនឹងធ្វើការល្អឡើយ ត្បិតអ្នករាល់គ្នា កំពុងតែដាក់គ្រឹះនៃកិច្ចការដ៏ធំ។ ហើយចេញពីការណ៍តូចតាច នោះបណ្តាលឱ្យមានការណ៍ដ៏ធំធេងឡើង" (គ. និង ស. 64:33)។ ភាពខ្ជាប់ខ្ជួនគឺជា គោលការណ៍គន្លឹះ នៅពេលយើងដាក់គ្រឹះនៃកិច្ចការធំមួយ នៅក្នុងជីវិតរស់នៅរបស់យើងម្នាក់១ ហើយនៅពេល យើងប្រែក្លាយកាន់តែមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានរបស់យើងខ្លាំងឡើង។

ការខ្ជាប់ខ្ជួនក្នុងគេហដ្ឋានរបស់យើង គឺជាមូលហេតុមួយទៀតដ៏សំខាន់។ ការស្តីបន្ទោសខ្លាំងបំផុតជាច្រើនរបស់ព្រះអង្គសង្គ្រោះគឺសំដៅចំទៅលើមនុស្សលាក់ពុត។ ព្រះយេស៊ូវព្រមានដល់ពួកសិស្សរបស់ទ្រង់អំពីពួកអាចារ្យ និង ពួកផារិស៊ីថាៈ "កុំឱ្យប្រព្រឹត្តតាមអំពើរបស់គេឡើយ ត្បិតគេគ្រាន់តែថា តែមិនធ្វើតាមទេ" (ម៉ាថាយ 23:3)។ ការដាស់តឿនដ៏ខ្លាំងនេះ កំពុងតែត្រូវបានផ្តល់ជាដំបូន្មានយ៉ាងខ្សឹកខ្សួលដើម្បី "សម្តែងចេញនូវសេចក្តីស្រឡាញ់---ហើយបង្ហាញវា" ដើម្បី "ថ្លែងទីបន្ទាល់---ហើយរស់នៅតាម" និងដើម្បី "នៅខ្ជាប់ខ្ជួន"។

ភាពលាក់ពុតនៅក្នុងជីវិតរស់នៅរបស់យើង ងាយស្រួល និងមើលឃើញ និងជាមូលហេតុនៃការបំផ្លាញដ៏ធំបំផុតនៅក្នុងគេហដ្ឋានរបស់យើងផ្ទាល់ ។ ហើយជាញឹកញាប់ កូនៗគឺជាអ្នកដឹង ហើយអាក់អន់ចិត្តបំផុត នៅពេលពួកគេដឹងថា ជាការលាក់ពុត ។ ការថ្លែងជាសាធារណៈអំពីសេចក្ដីស្រឡាញ់ តែសកម្មភាពនៃសេចក្ដីស្រឡាញ់ជាឯកជនត្រូវបានអវត្តមាននៅក្នុងផ្ទះ វាគឺជាការលាក់ពុត---ហើយធ្វើឱ្យគ្រឹះនៃកិច្ចការធំទន់ខ្សោយ ។ ការប្រកាសទីបន្ទាល់ជាសាធារណៈ នៅពេលគ្មានភាពស្មោះត្រង់ និងការគោរពប្រតិបត្តិនៅក្នុងគេហដ្ឋានរបស់យើង វាគឺជាការលាក់ពុត---ហើយវាចាក់ទំលាយគ្រឹះនៃកិច្ចការដ៏ធំ ។ ព្រះបញ្ញត្តិចែងថា "កុំឱ្យធ្វើជាទីបន្ទាល់ក្លែងទាស់នឹងអ្នកជិតខាងខ្លួនឱ្យសោះ" (និក្ខមនំ 20:16) វាមានអត្ថន័យចំបំផុតចំពោះភាពលាក់ពុតនៅក្នុងខ្លួនយើងម្នាក់ៗ ។ យើងចាំបាច់ត្រូវតែមាន ហើយប្រែក្លាយជាមនុស្សកាន់តែ ខ្ជាប់ខ្ជួន ។ "ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសំដី កិរិយាប្រព្រឹត្ត សេចក្ដីស្រឡាញ់ សេចក្ដីជំនឿ និងសេចក្ដីបរិសុទ្ធ" (ធីម៉ូថេទី 1 4:12) ។

នៅពេលយើងស្វែងរកជំនួយរបស់ព្រះអម្ចាស់ ហើយនៅក្នុងកម្លាំងរបស់ទ្រង់ នោះយើងអាចកាត់បន្ថយភាពខុសគ្នារវាងអ្វីដែលយើងនិយាយ និងអ្វីដែលយើងធ្វើបន្តិចម្ដងៗ រវាងការសម្ដែងចេញនូវសេចក្ដីស្រឡាញ់ និងការបង្ហាញសេចក្ដីស្រឡាញ់ខ្ជាប់ខ្ជួន រវាងការថ្លែងទីបន្ទាល់ និងការរស់នៅតាមដោយខ្ជាប់ខ្ជួន ។ យើងអាចប្រែក្លាយជាមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង នៅពេលយើងកាន់តែស្មោះត្រង់នៅក្នុងការរៀនសូត្រ ការរស់នៅតាម និង ការស្រឡាញ់ដំណឹងល្អដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។

**ទីបន្ទាល់**

"អាពាហ៍ពិពាហ៍រវាងបុរស និងស្រី គឺតែងតាំងឡើងដោយព្រះ ហើយ... គ្រួសារជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើតសំរាប់គោលដៅដ៏អស់កល្បជានិច្ចនៃកូនចៅរបស់ព្រះអង្គ..." ("The Family: A Proclamation to the World" *Liahona* ខែ តុលា ឆ្នាំ 2004 ទំព័រ 49) ។ សំរាប់មូលហេតុសំខាន់ដ៏នៅអស់កល្បទាំងនេះ និងមូលហេតុដទៃទៀត យើងគួរតែ មានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង ។

សូមឱ្យប្ដីឬប្រពន្ធ កូនចៅ និងឪពុកម្ដាយគ្រប់រូបត្រូវបានប្រទានពរឱ្យ ដើម្បីទំនាក់ទំនង និងទទួលសេចក្ដីស្រឡាញ់ ដើម្បីថ្លែង និងត្រូវបានស្អាងដោយទីបន្ទាល់រឹងមាំ ហើយកាន់តែមានភាពខ្ជាប់ខ្ជួននៅក្នុងរឿងដែលហាក់ដូចជាតូចៗដែលវាជារឿងសំខាន់បំផុត ។

នៅក្នុងការតស៊ូដ៏សំខាន់ទាំងនេះ យើងនឹងមិនត្រូវបានទុកឱ្យនៅម្នាក់ឯងនោះទេ ។ ព្រះវរបិតាសួគ៌របស់យើង និងព្រះរាជបុត្រាសំណប់របស់ទ្រង់មានព្រះជន្មរស់ ។ ទ្រង់ទាំងពីរអង្គស្រឡាញ់យើង ហើយស្គាល់ស្ថានភាពរបស់យើង ហើយទ្រង់នឹងជួយយើងឱ្យកាន់តែមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង ។ ខ្ញុំថ្លែងសេចក្ដីពិតទាំងនេះនៅក្នុងព្រះនាមដ៏ពិសិដ្ឋរបស់ ព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។